# ឧទាហរណ៍៣អំពី
# “ការទាញព្រ័ត្រក្នុងពិធីឡើងអ្នកតានៅខេត្តកំពង់ធំ”

“***ព្រ័ត្រ***” គឺជាពាក្យខ្ចីពីភាសាសំស្ក្រឹត “***វរត្រ***” សំដៅលើខ្សែផ្សេងៗដែលគេវេញ។ ព្រ័ត្រច្រើនសំដៅលើខ្សែវេញដែលជាប់មាំមួន ពោល គឺពុំមែនគ្រាន់តែជាខ្សែជាចំណងធម្មតាឡើយ។ ទោះជាសំដៅទៅរកខ្សែដែលជាប់ ក៏គប្បីយើងកុំច្រឡំនឹង “***ពួរ***” ដែលជាខ្សែវេញជាប់មាំមួនដែរ តែសម្រាប់ចងវត្ថុដែលធំ ឬដែលធ្ងន់ឲ្យជាប់ទៅនឹងអ្វីមួយមិនឲ្យរបូតរសាត់។ លោក ស៊ីយ៉ុន សុភារិទ្ធ ជាបុរាណវិទូខ្មែរយល់ថា ព្រ័ត្រអាចសំដៅទៅវត្ថុដែលមានតួនាទីពីរខុសគ្នា៖ មួយ៉ាងជាខ្សែសម្រាប់ទាក់សត្វ មួយ៉ាងទៀតជាខ្សែសម្រាប់ទាញឱ្យដាច់ក្នុងការប្រកួតគ្នាដែលមានលក្ខណៈជាកិច្ចពិធីផង។ នៅក្នុងអត្ថបទនេះ ខ្ញុំលើកយកឧទាហរណ៍នៃការទាញព្រ័ត្រចំនួន៣កន្លែងផ្សេងៗគ្នានៅក្នុងខេត្តកំពង់ធំ ហើយគេលេងនៅក្នុងពិធីឡើងអ្នកតាដូចគ្នា។ **ឧទាហរណ៍ទី១**នេះ គឺការទាញព្រ័ត្រនៅក្នុងពិធីឡើងអ្នកតាក្នុងភូមិរកា សង្កាត់ស្រយូវ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។ ព្រ័ត្រសម្រាប់ទាញនេះ គេធ្វើអំពីដើមឫស្សី ពោល គឺគេយកឫស្សីចំនួនពីរដើមមកថ្លក់ជាប់គ្នា ហើយឱ្យក្មេងៗទាញ និងមានមនុស្សចាស់ជាអ្នកផ្តួចផ្តើមការទាញនេះ។ មើលមួយភ្លែតយើងឃើញដូចជាកម្សាន្តទូទៅ ប៉ុន្តែវាមានលក្ខណៈជាកិច្ចពិធីច្បាស់ណាស់ ដ្បិតការទាញព្រ័ត្រឫស្សីនេះ គេទាញនៅក្នុងកិច្ចបញ្ជូនក្នុងពិធីឡើងអ្នកតា។ ជាទូទៅនៅតំបន់ផ្សេងៗ យើងធ្លាប់ឃើញតែគេបញ្ជូនដោយធ្វើជាពៃ សង្សឹក និងមានទាំងមាន់ក្តាងផង សម្រាប់ឱ្យក្មេងៗយកទៅដាក់ចោលនៅទីស្រែ ហើយភាគច្រើននៅខាងត្បូងរោងអ្នកតា។ ការទាញព្រ័ត្រឫស្សីក្នុងពេលបញ្ជូននេះ គឺតម្រូវឱ្យក្មេងៗទាញព្រ័ត្រនេះឱ្យដាច់ប្រសិនបើពុំដាច់ទេ គឺគេយកកាំបិតមកកាត់ខ្វះៗដើម្បីឱ្យងាយទាញដាច់។ ការទាញព្រ័ត្រឫស្សីក្នុងពិធីឡើងអ្នកតានៅភូមិរកានេះ គេប្រារព្ធឡើងនៅចុងខែចេត្រ ដើមខែពិសាខ ពោល គឺបន្ទាប់ពីចូលឆ្នាំខ្មែរបានបញ្ចប់។ យើងពិនិត្យមើលទៅអាចមានន័យពីរយ៉ាង ពោល គឺទី១ គេទាញឱ្យដាច់ក្នុងន័យផ្តាច់ឧបទ្រពចង្រៃឲ្យអស់ចេញពីភូមិស្រុក និងទី២អាចជាផ្តាច់ព្រ័ត្រក្នុងន័យឆ្លងចេត្រចូលពិសាខ ដ្បិតដើមខែពិសាខនេះហើយដែលជាពេលគេបើករដូវធ្វើស្រែចម្ការ (រូបលេខ ១-៤)។ **ឧទាហរណ៍ទី២** គឺការទាញព្រ័ត្រនៅក្នុងពិធីឡើងអ្នកតានៅភូមិតន្ទុកុមារ ឃុំកំពង់ស្វាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ដែលគេប្រារព្ធឡើងនៅចុងខែចេត្រ ដើមខែពិសាខដូចនៅភូមិរកាខាងលើដែរ។ ការលេងទាញព្រ័ត្រនេះ គេពុំមានប្រើប្រាស់ខ្សែព្រ័ត្រឫស្សីដូចភូមិរកា ឬខ្សែព្រ័ត្រអ្វីផ្សេងឡើយ។ ការទាញព្រ័ត្រនេះ គេធ្វើឡើងដោយមនុស្សចាស់ក្មេងពីរក្រុម ដែលក្រុមនីមួយៗមានគ្នាតិច ឬច្រើន

អត្ថបទដោយ៖ **លោក ម៉ង់ វ៉ាលី**

ចាប់តោងចង្កេះបន្តគ្នា រីឯអ្នកខាងមុខត្រូវយកដៃចាប់គូភាគីម្ខាងទៀត ហើយមានកំណត់ខ្សែបន្ទាត់ឈ្នះចាញ់។ បើភាគីខាងណាឈានជើងចូលខ្សែបន្ទាត់ភាគីម្ខាងទៀត ភាគីនោះនឹងចាញ់។ ពិធីនេះមើលទៅជាការកម្សាន្ត តែក៏បង្កប់ដោយអត្ថន័យមិនសូវខុសគ្នា ប៉ុន្មានពីព្រ័ត្រឫស្សីខាងលើដែរ ដ្បិតនេះជាកិច្ចដែលធ្វើឡើងជាប្រចាំ និងច្រើនជំនាន់មកហើយ បើទោះបីគេមិនធ្វើក្នុងពេលបញ្ចូនដូចភូមិរកាខាងលើក៏ដោយ (រូបលេខ៥-៨)។ **ឧទាហរណ៍ទី៣** គឺការទាញព្រ័ត្រនៅក្នុងពិធីឡើងអ្នកតាភូមិដងអន្ទាក់ ស្ថិតនៅភាគពាយព្យតំបន់ប្រាសាទសំបូរព្រៃគុកប្រមាណ៤គ.ម។ ពិធីនេះគេប្រារព្ធឡើងនៅខែមាឃធំ ខុសពីពិធីទាំងពីរខាងលើ។ រីឯខ្សែព្រ័ត្រគេមិនប្រើឫស្សី ផ្តៅ អ្វីឡើយ គេប្រើប្រាស់ខ្សែពួរធម្មតា។ ការលេងទាញព្រ័ត្រនេះទៀតសោត មានលក្ខណៈជាទូទៅដូចការផ្សេងៗតាមវត្តអារាមនៅរដូវចូលឆ្នាំខ្មែរដែរ ពោល គឺគេចែកមនុស្សប្រុសស្រីក្មេងចាស់ជាពីរក្រុមទាញមិនឱ្យដាច់ខ្សែទេ គ្រាន់តែមានខ្សែបន្ទាត់ឈ្នះចាញ់។ ការទាញព្រ័ត្រនេះជាល្បែងប្រជាប្រិយក្នុងពិធីឡើងអ្នកតា តែបើពិនិត្យយូរទៅក៏អាចយល់ថាជាកិច្ចមួយដូចពិធីពីរខាងលើដែរ (រូបលេខ ៩-១០)។

អត្ថបទដោយ៖ លោក ម៉ង់ វ៉ាលី




រូបលេខ១-២៖ កិច្ចទាញព្រ័ត្រនៅភូមិរកា




រូបលេខ៣-៤៖ កិច្ចទាញព្រ័ត្រនៅភូមិរកា

KHMER CIVILIZATION




រូបលេខ៥-៦៖ កិច្ចទាញព្រ័ត្រនៅភូមិឥន្ទកុមារ

អត្ថបទដោយ៖ លោក ម៉ង់ វ៉ាលី







រូបលេខ៧-៨៖ កិច្ចទាញព្រ័ត្រនៅភូមិឥន្ទកុមារ





រូបលេខ៩-១០៖ កិច្ចទាញព្រ័ត្រនៅភូមិដងអន្ទាក់

អត្ថបទដោយ៖ លោក ម៉ង់ វ៉ាលី